ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ: ០១៧ សហវ

# សារាចរណែនាំ

## ស្តីពីការអនុវត្តថវិកាខេត្ត ក្រុង ឆ្នាំ ២០០៧

ច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/ ១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ។ ដោយផ្អែកលើច្បាប់នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ ។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១៧០ អនក្រ.ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ និងអនុក្រឹត្យលេខ ១៧១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧។ ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ និងអនុក្រឹត្យនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសលេខ ១៤០២ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តប្លង់គណនេយ្យទូទៅនៃគណនេយ្យរដ្ឋ ប្រកាសលេខ ១៤០៣ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តប្លង់គណនេយ្យទូទៅនៃគណនេយ្យថវិកាខេត្ត ក្រុង ប្រកាសលេខ ១៤០៤ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តប្លង់គណនេយ្យទូទៅនៃគណនេយ្យថវិកាស្រុក ខណ្ឌ ប្រកាសលេខ ១៤០៥ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងកិច្ចដំណើរការគណនីនៃរដ្ឋទេយ្យចំណូល ប្រកាសលេខ ១៤០៩ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាខេត្ត ក្រុង ស្រុក ខណ្ឌ ប្រកាសលេខ ១៤១៦ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ប្រកាសលេខ ១៤១៧ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយឥណទានថវិកាផ្ទៃក្នុងជំពូកតាម គណនី និងអនុគណនី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ សារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការគ្រប់គ្រងរដ្ឋទេយ្យចំណូល សារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន និងសារាចរណែនាំលេខ ០១៥ សហវ. ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការកាត់បន្ថយនីតិវិធីនៃការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយសាធារណៈ ។ ដើម្បីអោយការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ មានដំណើការប្រកបដោយលទ្ធផលល្អ និងមានប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំលើការអនុវត្តថវិកាខេត្ត ក្រុង ឆ្នាំ ២០០៧ ដែលមានតាមលំដាប់លំដោយដូចតទៅ ៖

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣ ៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

# គ. អំពីចំណូល

## ១. ចំណូលសារពើពន្ធ

ចំពោះមុខសញ្ញាចំណូលសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតអោយប្រមូលសំរាប់ ជាគុណប្រយោជន៍នៃថវិកាខេត្ត ក្រុង នោះ ខេត្ត ក្រុងត្រូវជំរុញ និងតាមដានការអនុវត្តគោលនយោបាយនិងនីតិវិធីប្រមូលចំណូលរបស់មន្ត្រីពន្ធដារអោយបានត្រឹមត្រូវតាមបទប្បញ្ញាតិជាធរមាន និងត្រូវរួមចំណែកដាក់ចេញវិធានការជាក់ស្តែងសំរាប់ប្រភេទពន្ធដារនីមួយៗ ដើម្បីតម្រូវអោយអ្នកជាប់ពន្ធ បង់ពន្ធបានត្រឹមត្រូវគ្រប់គ្រាន់ និងទាន់ពេលវេលា ។ ទន្ទឹមនោះ ខេត្ត ក្រុងត្រូវចាត់អោយមានមន្ត្រីទទួលបន្ទុកប្រមូលទិន្នន័យស្ថិតិ និងកម្រងព័ត៌មាន ដែលជាមូលដ្ឋានក្នុងការប្រមូលពន្ធដារ សំរាប់ជាគុណប្រយោជន៍ដល់ថវិកាខេត្ត ក្រុង ដើម្បីជួយដល់មន្ត្រីពន្ធដារក្នុងការប្រមូលចំណូល និងធ្វើជាឯកសារបង្អែកក្នុងការរៀបចំគំរោងចំណូលពន្ធដារសំរាប់ឆ្នាំនីមួយៗ ។

## ២. ចំណូលពុំមែនសារពើពន្ធ

ចំពោះចំណូលពុំមែនសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតអោយប្រមូលសំរាប់ថវិកាខេត្ត ក្រុង នោះ ខេត្ត ក្រុងត្រូវយកចិត្តទុកដាក់ស្រាវជ្រាវកំណត់មុខសញ្ញាចំណូល ដែលត្រូវប្រមូលបង់ចូលរតនាគារអោយអស់ មិនត្រូវទុកចំណូលខ្លះ នៅដោយឡែក សំរាប់ចំណាយដោយឡែកក្រៅពីគំរោងចំណាយប្រចាំឆ្នាំឡើយ ។ ចំពោះចំណូលពុំមែនសារពើពន្ធដទៃទៀត ដែលខេត្ត ក្រុង បានប្រមូលក្រៅពីការអនុញ្ញាតដោយច្បាប់ ក៏ត្រូវបង់ចូលថវិកាខេត្ត ក្រុងដែរជៀសវាងទុកចំណូលនោះដោយឡែក សំរាប់ចំណាយដោយឡែក គ្មានតម្លាភាព ។ ចំពោះមុខសញ្ញាចំណូលដែលបានកំណត់រួចហើយ បើក្នុងលក្ខណៈដែលត្រូវប្រមូលតាមវិធីដេញថ្លៃជាសាធារណៈនោះ ត្រូវធ្វើអោយមានតម្លាភាពពិតប្រាកដ មិនត្រូវបង្កើតការដេញថ្លៃតែរូបភាពនោះទេ ទន្ទឹមនោះត្រូវយកចិត្តទុកដាក់ជំរុញការបង់ចំណូលអោយបានត្រឹមត្រូវតាមការកំណត់ដែលមានចែងក្នុងកិច្ចសន្យា ។

ដោយឡែកសំរាប់ខេត្តបាត់ដំបង និងខេត្តសៀមរាបត្រូវជួយបង្កគ្រប់លក្ខណៈសម្បត្តិអោយការប្រមូលចំណូលពីច្រកចេញចូលតែមួយរបស់ស្រុកបាត់ដំបង និងស្រុកសៀមរាបប្រព្រឹត្តទៅបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព ។

## ៣. ចំណូលឧបត្ថម្ភពីថវិការដ្ឋ

ចំពោះខេត្ត ក្រុង ដែលត្រូវបំពេញតុល្យភាពដោយការឧបត្ថម្ភពីថវិការដ្ឋ ទោះបីបានកត់ត្រាតួលេខចំណូលឧបត្ថម្ភពីថវិការដ្ឋនៅក្នុងគំរោងថវិការបស់ខ្លួនក៏ដោយ ក៏មិនមានន័យថា ថវិការដ្ឋត្រូវតែដាច់ខាតឧបត្ថម្ភតាមចំនួននោះទេ ។ ចំណូលឧបត្ថម្ភពីថវិការដ្ឋ គឺត្រូវពិនិត្យឧបត្ថម្ភជូនខេត្ត ក្រុង ដោយផ្អែកទៅតាមស្ថានភាពជាក់ស្តែងនៃតុល្យភាពថវិការដ្ឋ និងទៅតាមសភាពការណ៍ជាក់ស្តែងនៃការអនុវត្តចំណូល ចំណាយថវិការបស់ខេត្ត ក្រុង ។

### ៣.១ ចំណូលឧបត្ថម្ភតុល្យភាពពីថវិការដ្ឋ

ចំពោះចំណូលនេះ ខេត្ត ក្រុងត្រូវធ្វើសំណើសុំឧបត្ថម្ភតុល្យភាពប្រចាំត្រីមាសនីមួយៗ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ ។ នៅដើមត្រីមាសទី ១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងផ្តល់ថវិកាឧបត្ថម្ភតុល្យភាពជូនខេត្ត ក្រុង ដោយមិនបាច់មានការស្នើសុំទេ ។ ដោយឡែកសំរាប់ត្រីមាសទី ២ ទី ៣ និងទី៤ខេត្ត ក្រុងត្រូវធ្វើសំណើសុំថវិកាឧបត្ថម្ភតុល្យភាពនៅដើមខែនៃចុងត្រីមាសមុន សំរាប់ត្រីមាសបន្ទាប់ដោយភ្ជាប់មកជាមួយនូវឯកសារជាមូលដ្ឋាននៃការស្នើសុំឧបត្ថម្ភតុល្យភាព ។

### ៣.២ ចំណូលឧបត្ថម្ភពីថវិការដ្ឋសំរាប់វិនិយោគសាធារណៈ

ចំណុចនេះ គ្រាន់តែជាការផ្ទេរឥណទានថវិការដ្ឋសំរាប់អនុវត្តនូវកម្មវិធីចំណាយវិនិយោគសាធារណៈ នៅក្នុងថវិកាខេត្ត ក្រុង ដូច្នេះពេលស្នើសុំគឺខេត្ត ក្រុង ត្រូវធ្វើសំណើត្រង់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែម្តង ។ ការស្នើនេះ ចែកចេញជាពីរយ៉ាង ៖

**ទី១. ឧបត្ថម្ភសំរាប់ចូលនិធិចម្រុះ**

ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិកាខេត្ត ក្រុង ឬ ប្រកាសបន្ថែមឥណទានត្រូវធ្វើសំណើ ដោយភ្ជាប់មកជាមួយនូវគំរោងកម្មវិធីវិនិយោគសាធារណៈ នៃហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលត្រូវអនុវត្តនៅខេត្ត ក្រុងរបស់ខ្លួន ។

**ទី២. ឧបត្ថម្ភវិនិយោគដោយថវិការដ្ឋ**

ផ្អែកលើតួលេខដែលបានគ្រោងក្នុង សៀវភៅថវិកាខេត្ត ក្រុង ឬប្រកាសបន្ថែមឥណទាន ត្រូវធ្វើសំណើ ដោយភ្ជាប់មកជាមួយនូវឯកសារដែលបានធ្វើលទ្ធកម្មសាធារណៈរួចតាមការដ្ឋាននីមួយៗ ។

## ខ. អំពីចំណាយ

**១. ចំណាយចរន្ត :**

ចំណាយចរន្តត្រូវអនុវត្តអោយបានម៉ឺងម៉ាត់ ទៅតាមគោលការណ៍ និងនីតិវិធីដូចគ្នា នៃចំណាយថវិការដ្ឋដែរពោលគឺ ៖

- អំពីចំណាយបៀវត្សត្រូវអនុវត្តតាមរយៈភ្នាក់ងារបើកផ្តល់ ។ ចំពោះបៀវត្សមូលដ្ឋាន និងប្រាក់កំរៃបុគ្គលិកអណ្តែត ភ្នាក់ងារជាប់កិច្ចសន្យា ត្រូវអនុវត្តតាមសេចក្តីសំរេចទទួលស្គាល់របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- អំពីចំណាយតូចតាច និងចំណាយចាំបាច់បន្ទាន់ គឺត្រូវអនុវត្តតាមរដ្ឋទេយ្យបុរេប្រទានដែលកំណត់ឡើងដោយដីការបស់ខេត្ត ក្រុង ។ ពេលដកប្រាក់ពីរតនាគារ រដ្ឋទេយ្យករត្រូវមានប័ណ្ណដកប្រាក់ និងលិខិតឱទ្ទេសនាមរបស់អង្គភាព (ពុំចាំបាច់ធ្វើលិខិតស្នើសុំថ្លែងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ) ។
- អំពីចំណាយចរន្តផ្សេងៗទៀត គឺត្រូវអនុវត្តទៅតាមនីតិវិធីទូទាត់ត្រង់ជូនអ្នកផ្គត់ផ្គង់ ក្រោយពេលដែលទំនិញ ឬសេវានានា ត្រូវបានអនុវត្តរួចហើយ ។
- ចំពោះជំពូក ០៩ "ចំណាយមិនបានគ្រោងទុក" ខេត្ត ក្រុងមិនត្រូវអនុវត្តចំណាយជំពូកនេះដោយផ្ទាល់ទេ ។ នៅពេលមានតំរូវការចំណាយខេត្ត ក្រុងត្រូវធ្វើសំណើសុំការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីបង្វែរឥណទានពីជំពូកនេះ ទៅជាប្រយោជន៍ដល់ជំពូកចំណាយដទៃទៀត ទៅតាមតំរូវការចំណាយជាក់ស្តែងនីមួយៗ ជាពិសេសអាទិភាពសំរាប់តំរូវការប្រាក់បៀវត្ស និងការងារអភិវឌ្ឍន៍ខេត្ត ក្រុង ។
- ដោយឡែកសំរាប់ខេត្តបាត់ដំបង និងខេត្តសៀមរាប ឯកឧត្តមអភិបាលខេត្ត ត្រូវចេញដីកាផ្ទេរឥណទាន និងផ្ទេរអាណាប័កជូនអភិបាលស្រុកបាត់ដំបង និងស្រុកសៀមរាប អោយអនុវត្តនូវចំនួនឥណទានដែលខេត្តបានពិភាក្សាឯកភាពជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចដែលបានបែងចែក និងភ្ជាប់ជាមួយក្នុងសៀវភៅថវិការបស់ខេត្តបាត់ដំបង និងខេត្តសៀមរាបរួចហើយនោះ ។

**២. ចំណាយជាមូលធន :**

ចំពោះការចំណាយជាមូលធនគឺចែកចេញជាពីរ ៖

**ទី១. ចំណាយសំរាប់ចូលមូលធនវិនិយោគ :**

ក្នុងពេលអនុវត្តខេត្ត ក្រុងត្រូវធ្វើអាណត្តិដោយគ្រាន់តែភ្ជាប់ តាមទូវគំរោងកម្មវិធីវិនិយោគសាធារណៈនៃហិរញ្ញប្បទានពីក្រៅប្រទេសតែប៉ុណ្ណោះ ។ រតនាគារខេត្ត ក្រុង ត្រូវបើកផ្តល់ឬផ្ទេរឥណទាននេះទៅក្នុងគណនីម្ចាស់ជំនួយនៅរតនាគារខេត្ត ក្រុង ឬធនាគារ (បើមាន) ។

**ទី២. ចំណាយវិនិយោគ :**

ចំណាយវិនិយោគ ទោះជាហិរញ្ញប្បទានដោយថវិកាខេត្ត ក្រុង ឬហិរញ្ញប្បទានដោយថវិការដ្ឋឧបត្ថម្ភក៏ដោយគឺត្រូវតែបំពេញបែបបទ និងអនុវត្តអោយបានត្រឹមត្រូវទៅតាមនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន និងធ្វើអាណត្តិទូទាត់អោយបានត្រឹមត្រូវតាមការិយបច្ឆេទដែលបានកំណត់ក្នុងសៀវភៅបន្ទុក ឬ កិច្ចសន្យា ។

**៣. ចំណាយបន្ថែមលើសពីគំរោងចំណាយថវិកាខេត្ត ក្រុងប្រចាំឆ្នាំ :**

យោងប្រការ ១២ នៃ ប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់ខេត្ត ក្រុង បានចែងថា ឲ្យនៅក្នុងឆ្នាំថវិកាប្រសិនបើចំណូលជាក់ស្តែងនៃថវិការបស់ខេត្ត ក្រុង បានកើនលើសពីគំរោងចំណូលប្រចាំឆ្នាំ ដែលបានគ្រោងទុកនោះឥណទានចំណាយថវិកាអាចត្រូវបង្កើនឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមកំរិតចំណូលលើសដែលបានចុះកិច្ចបញ្ជីការ ។

ដូច្នេះ នៅត្រីមាសទី ៤ ខេត្ត ក្រុងត្រូវពិនិត្យការអនុវត្តចំណូលរបស់ខ្លួន ដោយមានមូលដ្ឋានជាក់លាក់ដែលអាចប្រមូលចំណូលបានយ៉ាងពិតប្រាកដ រួចប្រៀបធៀបជាមួយគំរោងចំណូលប្រចាំឆ្នាំ ។ ប្រសិនបើមានចំណូលលើសពីគំរោងចំណូលប្រចាំឆ្នាំ ខេត្ត ក្រុងអាចស្នើសុំបន្ថែមលើគំរោងចំណាយប្រចាំឆ្នាំសំរាប់ចំណាយជាគុណប្រយោជន៍របស់ខេត្ត ក្រុង ដែលជាចំណាយសំរាប់វិនិយោគអភិវឌ្ឍន៍ខេត្ត ក្រុង ហើយខេត្ត ក្រុងត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវគំរោងចំណាយលំអិតតាមការដ្ឋាននីមួយៗផង ។

## គ. ការបង្វែរឥណទាន

ចាប់ពីឆ្នាំ ២០០៧ តទៅ ការរៀបចំគំរោង និងការអនុវត្តថវិកាត្រូវកត់ត្រាទៅតាមប្លង់គណនេយ្យ និងមាតិកាថវិកាថ្មី ដែលមានបែងចែកជាក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី ។

ការបង្វែរ (និយ័តភាព) ឥណទានត្រូវបានអនុញ្ញាតដោយអនុវត្តចាប់ពីត្រីមាសទី ២ ។ ក្នុងករណីមានតំរូវការចាំបាច់ត្រូវបង្វែរឥណទានពីអនុគណនីមួយទៅអនុគណនីមួយ ពីគណនីមួយទៅគណនីមួយ និងពីជំពូកមួយទៅជំពូកមួយផ្សេងទៀតនោះខេត្ត ក្រុង ត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍អនុវត្តចំណាយដើមឆ្នាំ និងរបាយការណ៍ប៉ាន់ស្មានចំណាយចុងឆ្នាំ ។

## ឃ. ការរៀបចំកម្មវិធីចំណូល ចំណាយ

ផ្អែកលើគំរោងថវិកាប្រចាំឆ្នាំ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានប្រកាសជូន ខេត្ត ក្រុងទាំងអស់ត្រូវរៀបចំកម្មវិធីចំណូល ចំណាយថវិកាប្រចាំត្រីមាស និងត្រូវផ្ញើកម្មវិធីចំណូល ចំណាយនោះទៅរតនាគារខេត្ត ក្រុង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ យ៉ាងយូរបំផុតមួយសប្តាហ៍នៃដើមត្រីមាសនីមួយៗ ។

ដោយឡែកសំរាប់ត្រីទី ២ ទី ៣ និងទី ៤ ពេលផ្ញើកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ គឺដាច់ខាតត្រូវតែភ្ជាប់មកជាមួយនូវរបាយការណ៍ស្តីពីការអនុវត្តថវិកានៃត្រីមាសមុន។ កម្មវិធីចំណូល ចំណាយប្រចាំត្រីមាស គឺជាឯកសារគោល ដើម្បីវិភាគក្នុងការផ្តល់ឧបត្ថម្ភធនពីថវិការដ្ឋ ។

ក្នុងការអនុវត្តថវិការបស់សាលាខេត្ត ក្រុង ក្រុមហិរញ្ញវត្ថុត្រូវធ្វើជាលេខាធិការអោយអភិបាលខេត្ត ក្រុង ក្នុងការរៀបចំរាល់សំណុំលិខិត ឯកសារទាំងអស់ដែលពាក់ព័ន្ធដល់ការងារជំនាញហិរញ្ញវត្ថុ ថវិកា ដើម្បីជំរុញអោយការអនុវត្តចំណូល និងចំណាយថវិការបស់សាលាខេត្ត ក្រុងសំរេចបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព ។

ខាងលើនេះគឺជាការណែនាំបន្ថែមក្នុងកិច្ចប្រតិបត្តិការថវិកាខេត្ត ក្រុងអោយចំទិសដៅនិងមានប្រសិទ្ធភាពសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដោយឡែកប្រកាសណែនាំស្តីពីកិច្ចប្រតិបត្តិការអនុវត្តថវិកាខេត្ត ក្រុង លេខ ២០៥ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលមិនផ្ទុយនឹងប្រកាសនេះ នៅតែរក្សាសុពលភាពដដែល ។ល។

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ ២០០៦

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

(ដើម្បីជូនជ្រាប)

- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក្រុង
- គ្រប់រតនាគារខេត្ត ក្រុង
- គ្រប់សាខាពន្ធដារខេត្ត ក្រុង

(ដើម្បីអនុវត្ត)

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៥៤០៩ សហវ.ប្រក.

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ [illegible] ឆ្នាំ ២០០៦

# ប្រកាស

## ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាខេត្ត ក្រុង និងស្រុក ខណ្ឌ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ២០០៤ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨/ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រម ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាបស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង
- បានឃើញព្រះរាជក្រម នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់ខេត្ត ក្រុង
- បានឃើញប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## សម្រេច

**ប្រការ ១:** ត្រូវបានដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាខេត្ត ក្រុង និងស្រុក ខណ្ឌ ដែលចែកជាចំណាត់ថ្នាក់ចំណូល និងចំណាត់ថ្នាក់ចំណាយ និងដែលបានអនុញ្ញាតដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។ ចំណាត់ថ្នាក់ចំណូល និងចំណាត់ថ្នាក់ចំណាយ ត្រូវបានបែងចែកជាក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី ដូចមានចែងក្នុងឧបសម្ព័ន្ធ ១ និងឧបសម្ព័ន្ធ ២ ភ្ជាប់ជាមួយនឹងប្រកាសនេះ ។

**ប្រការ ២:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយ នឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍

**ប្រការ ៣:** ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ តទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចំលងជូន:**
- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច

«ដើម្បីជ្រាបជាពត៌មាន»
- គ្រប់ខេត្ត ក្រុង
- ស្រុក ខណ្ឌ

«ដើម្បីមុខការ»
- កាលប្បវត្តិ - ឯកសារ

# ឧបសម្ព័ន្ធ១

## មាតិកាចំណូលថវិកាខេត្ត-ក្រុង

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល |
|---|---|---|---|
| | | | **សរុបរួមចំណូលថវិកាខេត្ត ក្រុង** |
| | | | **I - សរុបចំណូលចរន្ត** |
| | | | **ក. ក្រុមទី១ : ចំណូលពិត ( ប្រភេទទី១ + ប្រភេទទី២ )** |
| | | | **ប្រភេទទី ១ : ចំណូលសារពើពន្ធ** |
| 70 | | | ចំណូលសារពើពន្ធ |
| | 701 | | ពន្ធលើបេតិកភ័ណ្ឌ |
| | | 7011 | ពន្ធប្រថាប់ត្រា . ពន្ធផ្ទេរមរតករវាងអ្នកនៅរស់ |
| | | 7012 | ពន្ធប្រថាប់ត្រា . ពន្ធផ្ទេរសិទ្ធិពីអ្នកស្លាប់ |
| | | 7013 | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ |
| | 702 | | ពន្ធលើទ្រព្យសម្បត្តិដែលបានកំណត់ |
| | | 7021 | អាករបំភ្លឺសាធារណៈ |
| | 703 | | ពន្ធលើសេវាដែលបានកំណត់ |
| | | 7031 | អាករលើការស្នាក់នៅ |
| | | 7032 | ពន្ធសត្តឃាត |
| | 704 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិឬការអនុវត្តន៍សកម្មភាព |
| | | 7041 | ពន្ធប៉ាតង់ |
| | | 7042 | ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានយន្តគ្រប់ប្រភេទ |
| | | 7043 | ពន្ធលើការផ្គត់ផ្គង់អគ្គិសនីរបស់សហគ្រាសឯកជនតាមខេត្ត ក្រុង |
| | | | **ប្រភេទទី ២ : ចំណូលមិនមែនសារពើពន្ធ** |
| 72 | | | **ផលខុននៃទ្រព្យសម្បត្តិរដ្ឋ** |
| | 721 | | ផលនៃការជួលដីធ្លី |
| | | 7211 | សម្បទានពីរ៉ែ |
| | | 7212 | ការជួលកន្លែងលក់ដូរក្នុងទីផ្សារ |
| | | 7213 | ចំណូលពីចំណតរថយន្ត |
| | | 7214 | ចំណូលពីចំណតជលយាន |
| 73 | | | **ផលខុនលើការលក់-ជួលទ្រព្យសម្បត្តិនិងសេវា** |
| | 731 | | សហគ្រាសសាធារណៈ-រដ្ឋបាល និង សេវាទ្រព្យសម្បត្តិ |
| | 732 | | ផលពីការគ្រប់គ្រងរដ្ឋបាល |
| | | 7321 | សេវាសុរិយោដី |
| | | 7322 | សេវាសំណង់ |
| | | 7323 | ចំណូលសំរាប់ទំរង់ការរដ្ឋបាល |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល |
|---|---|---|---|
| | | 7324 | ចំណូលពីការអនុញ្ញាតរដ្ឋបាល |
| | | 7328 | ចំណូលរដ្ឋបាលផ្សេងៗទៀត |
| | 733 | | ការជួលទ្រព្យសម្បត្តិអចល័ត |
| | | 7331 | ចំណូលពីសត្តឃាតដ្ឋាន |
| | | 7332 | ការជួលកន្លែងលក់ដូរក្នុងទីផ្សារ |
| | | 7333 | ចំណូលពីកំពង់ចម្លង |
| | | 7334 | ចំណូលពីឃ្លាំងត្រី និងពីកន្លែងបែងចែកផលិតផល |
| | | 7335 | ចំណូលពីភាស៊ីផ្សារ |
| 74 | | | **ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម** |
| | 741 | | ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម |
| 75 | | | **ការឧបត្ថម្ភធន** |
| | 751 | | ទាយជ្ជទានសំរាប់ដំណើរការដែលឧបត្ថម្ភដោយថវិការដ្ឋ |
| | 752 | | ផលចំណូលពីការបែងចែកដោយរដ្ឋលើការផាកពិន័យរបស់គយ |
| | 758 | | ចំណូលឧបត្ថម្ភថវិកាពីប្រភពផ្សេងៗ |
| 77 | | | **ផលផ្សេងៗនិងផលពិសេស** |
| | 775 | | ផលពីការលក់អចលកម្ម |
| | | | **ខ_ក្រុមទី ២ : ចំណូលតាមដីកា ( ប្រភេទទី៣ )** |
| | | | **ប្រភេទទី ៣ : ចំណូលតាមដីកា ( មិនឆ្លងកាត់សាច់ប្រាក់ )** |
| 77 | | | **ផលផ្សេងៗនិងផលពិសេស** |
| 78 | | | **ការងារនៃរដ្ឋខេត្ត** |
| | | | **II - សរុបចំណូលជាមូលធន** |
| | | | **ក_ក្រុមទី ១ : ចំណូលពិត ( ប្រភេទទី១ + ប្រភេទទី២ )** |
| | | | **ប្រភេទទី ១: ឧបត្ថម្ភធន** |
| 13 | | | **ឧបត្ថម្ភធនវិនិយោគ** |
| | 131 | | ឧបត្ថម្ភធនទទួលសំភារៈបរិក្ខាទូរភាគី |
| | | | **ប្រភេទទី ២ : ចំណូលតាមដីកា ( មិនឆ្លងកាត់សាច់ប្រាក់)** |
| | | | ............. |
| | | | .............. |
| | | | **ខ_ក្រុមទី ២ : ចំណូលតាមដីកា** |
| | | | **ប្រភេទទី ៣ : ចំណូលតាមដីកា ( មិនឆ្លងកាត់សាច់ប្រាក់)** |

# ឧបសម្ព័ន្ធ២

## មាតិកាចំណាយថវិកាខេត្ត-ក្រុង

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | | សរុបរួមចំណាយថវិកាខេត្ត-ក្រុង |
| | | | I - សរុបចំណាយចរន្ត |
| | | | ក.ក្រុមទី ១ : ចំណាយពិត (ប្រភេទទី១ + ប្រភេទទី២ + ប្រភេទទី៣ + ប្រភេទទី៤) |
| | | | ប្រភេទទី ១ : មធ្យោបាយសេវា |
| 60 | | | ការទិញ |
| | 601 | | សំភារៈផ្គត់ផ្គង់ថែទាំ |
| | | 6011 | សំភារៈផ្គត់ផ្គង់សំអាតនិងអនាម័យ |
| | | 6012 | សំភារៈផ្គត់ផ្គង់សំរាប់ថែទាំអាគារ |
| | | 6013 | សំភារៈផ្គត់ផ្គង់សំរាប់ថែទាំ ផ្លូវថ្នល់ ផ្លូវលំ ស្ពាន និងលូ |
| | | 6014 | សំភារៈផ្គត់ផ្គង់សំរាប់ថែទាំសំភារៈឧបករណ៍ |
| | | 6015 | ប្រេងឥន្ធនៈនិងប្រេងរំអិល |
| | 602 | | សំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល |
| | | 6021 | សំភារៈការិយាល័យនិងការបោះពុម្ព |
| | | 6022 | សៀវភៅមើល និង ឯកសារ |
| | | 6028 | ផ្សេងៗ |
| | 603 | | ស្បៀងអាហារ |
| | | 6031 | ស្បៀង |
| | 604 | | សំលៀកបំពាក់និងការតុបតែង |
| | | 6041 | ឯកសណ្ឋាន |
| | | 6042 | សំលៀកបំពាក់ការពារសុវត្ថិភាព |
| | | 6043 | មេដាយ( គ្រឿងឥស្សរិយយស ) |
| | | 6048 | ផ្សេងៗ |
| | 605 | | សំភារៈតូចតាច សង្ហារឹម និងសំភារៈបរិក្ខារ |
| | | 6051 | សំភារៈនិង បរិក្ខារ |
| | | 6052 | សង្ហារឹម |
| | | 6053 | សំភារៈប្រើប្រាស់ |
| | | 6058 | ផ្សេងៗ |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | 606 | | ថាមពល និង ទឹក |
| | | 6061 | អគ្គិសនី |
| | | 6062 | ទឹក |
| | | 6068 | ផ្សេងៗ |
| | 608 | | សំភារៈផ្គត់ផ្គង់ផ្សេងៗ |
| 61 | | | **សេវាខាងក្រៅ** |
| | 611 | | កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស |
| | 612 | | ការជួលមធ្យោបាយដឹកជញ្ជូន |
| | 613 | | ថ្លៃឈ្នួល និងបន្ទុក ( អសង្ហារឹម ) |
| | 614 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក |
| | 615 | | ការថែទាំ និងជួសជុល |
| | | 6151 | ការថែទាំដីធ្លី សួនច្បារ,រៀបជាផ្លូវ |
| | | 6152 | ការថែទាំ ទីផ្សារ សត្តឃាតដ្ឋាន និងអាគារសាធារណៈ |
| | | 6153 | ការថែទាំជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងប្រពន្ធ័លូ |
| | | 6154 | ការថែទាំបណ្តាញផ្សេងៗ |
| | | 6155 | ការថែទាំ និងជួសជុលឧបករណ៍ សំភារៈការិយាល័យ សំភារៈពត៌មានវិទ្យា និងទូរគមនាគមន៍ |
| | | 6156 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន |
| | | 6157 | ការថែទាំ និងជួសជុលសំភារៈឧបករណ៍បច្ចេកទេស |
| | 616 | | សោហ៊ុយធានារ៉ាប់រង |
| | 617 | | សោហ៊ុយសិក្សាពិសោធ៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ |
| | | 6171 | សោហ៊ុយសិក្សាពិសោធន៍ |
| | | 6172 | សោហ៊ុយនៃការប្រើប្រាស់សេវា |
| | | 6173 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ |
| | 618 | | សោហ៊ុយដឹកជញ្ជូន |
| | | 6181 | សំភារៈ និងទំនិញ |
| 62 | | | **សេវាខាងក្រៅផ្សេងៗ** |
| | 621 | | បុគ្គលិកខាងក្រៅ |
| | | 6211 | ភ្នាក់ងារជាតិជាប់កិច្ចសន្យា |
| | | 6212 | ភ្នាក់ងារបរទេសជាប់កិច្ចសន្យា |
| | | 6213 | បុគ្គលិកសមូហភាពសាធារណៈផ្សេងៗ |
| | 622 | | ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ |
| | | 6221 | សោហ៊ុយទទួលភ្ញៀវជាតិ |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | 6222 | សោហ៊ុយទទួលភ្ញៀវបរទេស |
| | | 6223 | ប្រជុំ -សិក្ខាសាលា និងសន្និសីទ |
| | | 6224 | សោហ៊ុយពិធីបុណ្យ |
| | | | . បុណ្យជាតិ និងបុណ្យប្រពៃណីយ៍ |
| | | | . បុណ្យចំរើនព្រះជន្មាយុព្រះមហាក្សត្រ |
| | | | . បុណ្យរុក្ខទិវា |
| | | | . បុណ្យផ្សេងៗទៀត |
| | | 6225 | ចំណាយសំរាប់វត្ថុអនុស្សាវរីយ៍ក្នុង និងក្រៅប្រទេស |
| | | 6226 | សោហ៊ុយសំរាប់ការតាំងពិពណ៌នៅក្នុងនិងក្រៅប្រទេស |
| | | 6227 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ |
| | 623 | | សោហ៊ុយជាវសារព័ត៌មាន និងឯកសារ |
| | 624 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស |
| | | 6241 | សោហ៊ុយដឹកជញ្ជូន |
| | | 6242 | សោហ៊ុយបេសកកម្ម |
| | | 6243 | សោហ៊ុយស្នាក់នៅ |
| | 625 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស |
| | | 6251 | សោហ៊ុយដឹកជញ្ជូន |
| | | 6252 | សោហ៊ុយបេសកកម្ម |
| | | 6253 | សោហ៊ុយស្នាក់នៅ |
| | 626 | | សោហ៊ុយទូរគមនាគមន៍ ទូរស័ព្ទគេឡិច និងទូរសារប្រៃសណីយ៍ |
| | | 6261 | សោហ៊ុយប្រៃសណីយ៍ |
| | | 6262 | សោហ៊ុយទូរគមនាគមន៍ |
| | 627 | | សោហ៊ុយធនាគារ |
| | 628 | | សោហ៊ុយផ្សេងៗ |
| 64 | | | **បន្ទុកបុគ្គលិក** |
| | 641 | | លាភការ និង ប្រាក់បំណាច់ នៃអំណាចសាធារណៈ |
| | | 6411 | ប្រាក់បំណាច់អភិបាលខេត្ត-ក្រុង |
| | | 6412 | ប្រាក់បំណាច់អភិបាលរងខេត្ត-ក្រុង |
| | | 6413 | លាភការទីប្រឹក្សា |
| | | 6414 | លាភការបេសកជន |
| | | 6419 | ការសង និងការបង្វិលវិញ |
| | 642 | | លាភការនិងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | 6421 | ប្រៀវត្សមូលដ្ឋាន |
| | | | . ចំនួន |
| | | | . ប្រភេទ |
| | | | . ខុទ្ទកាល័យ |
| | | 6422 | ប្រាក់បំណាច់មុខងារ |
| | | 6423 | ប្រាក់បំណាច់ម៉ោងបន្ថែម |
| | | 6424 | ប្រាក់បំណាច់តំបន់ |
| | | 6425 | ប្រាក់បំណាច់ទទួលខុសត្រូវ |
| | | 6426 | ប្រាក់បំណាច់ការងារធ្ងន់ និងប៉ះពាល់សុខភាព |
| | | 6429 | ការសង និងការបង្វិលវិញ |
| | 643 | | រង្វាន់ និងប្រាក់បំណាច់ផ្សេងៗទៀត |
| | | 6431 | កន្សោមអទិភាព |
| | | 6432 | ប្រាក់បំណាច់សំរាប់ប្រឡង-ប្រឡងប្រជែង |
| | | 6433 | រង្វាន់ |
| | | 6434 | ប្រាក់បំណាច់បុគ្គលិកក្រសួងផ្សេងៗ |
| | | 6438 | ផ្សេងៗ |
| | | 6439 | ការសង និងការបង្វិលវិញ |
| | 644 | | លាភការ និងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ និងបុគ្គលិកអណ្តែត |
| | | 6441 | ប្រៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ |
| | | 6442 | លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខ័ណ្ឌ |
| | | 6443 | ប្រៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត |
| | | 6444 | លាភការផ្សេងៗទៀតបុគ្គលិកអណ្តែត |
| | | 6449 | ការសង និងការបង្វិលវិញ |
| | 645 | | ប្រាក់វិភាជន៍សង្គម |
| | | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ |
| | | | . កូនមានអាយុតិចជាង១៥ ឆ្នាំ |
| | | | . កូនរៀនវិទ្យាល័យ អនុវិទ្យាល័យ |
| | | | . ប្រាក់បំណាច់អ្នកក្នុងបន្ទុក |
| | | 6452 | មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសំរាលកូន |
| | | 6453 | មរណៈភាព |
| | | 6454 | ឧបត្ថម្ភនិវត្តជន |
| | | 6455 | ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | 6456 | គ្រោះថ្នាក់ការងារ និងទុព្វលភាព |
| | | 6457 | ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ |
| | | 6458 | ផ្សេងៗ |
| | | 6459 | ការសង និងការបង្វិលវិញ |
| | | | ប្រភេទទី ២ : បន្ទុកហិរញ្ញវត្ថុ |
| 66 | | | បន្ទុកហិរញ្ញវត្ថុ |
| | | | ប្រភេទទី ៣ : អន្តរាគមន៍សាធារណៈ |
| 65 | | | ឧបត្ថម្ភកធន និងជំនួយសង្គម |
| | 651 | | ឧបត្ថម្ភកធនដល់រដ្ឋបាលដែនដី |
| | | 6511 | ឧបត្ថម្ភកធនស្រុក ខណ្ឌ |
| | | 6512 | ឧបត្ថម្ភកធនដល់ឃុំ សង្កាត់ |
| | | 6513 | ឧបត្ថម្ភគ្រឹះស្ថានសាធារណៈរដ្ឋបាល |
| | 652 | | ជំនួយសង្គមនិងប្រាក់វិភាជន៍ |
| | | 6521 | ជំនួយដល់ប្រជាជនក្រីក្រស់រាកពេទ្យ |
| | | 6522 | ជួយជនរងគ្រោះដោយធម្មជាតិ |
| | | 6528 | ចំណាយសង្គមផ្សេងៗទៀត |
| | 653 | | ឧបត្ថម្ភកធនដល់អង្គភាពមានលក្ខណៈសង្គមនិងវប្បធម៌ |
| | | 6531 | ឧបត្ថម្ភមណ្ឌលកុមារកំព្រា |
| | | 6532 | ឧបត្ថម្ភសហគមន៍ កីឡា និងវប្បធម៌ |
| | | 6533 | ឧបត្ថមកាកបាទក្រហម |
| | | | ប្រភេទទី ៤ : ចំណាយផ្សេងៗ |
| 63 | | | ពន្ធ និង អាករ |
| | 631 | | លតាប័ត្រ |
| | | | ខ.ក្រុមទី ២ : ចំណាយតាមដីកា និងចំណាយមិនបានគ្រោងទុក ( ប្រភេទទី៥ + ប្រភេទទី៦ ) |
| | | | ប្រភេទទី ៥ : ចំណាយតាមដីកា ( មិនឆ្លងសាច់ប្រាក់ ) |
| 67 | | | បន្ទុកពិសេស |
| | 671 | | គណនេយ្យដែលទទួលស្គាល់តែទារមិនបាន |
| | 675 | | តំលៃគណនេយ្យនៃចំណែកសកម្មបានលក់ (តំលៃនៅសល់) |
| 68 | | | ទាយជ្ជទានអោយដល់វិលស់អចលកម្ម |
| | 681 | | ទាយជ្ជទានអោយដល់វិលស់អចលកម្មអរូបី |
| | 682 | | ទាយជ្ជទានអោយដល់វិលស់អចលកម្មរូបី |
| | | | ប្រភេទទី ៦ : ចំណាយមិនបានគ្រោងទុក |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| 09 | | | ចំណាយមិនបានគ្រោងទុក |
| | | | **II - សរុបចំណាយជាមូលធន** |
| | | | **ក_ក្រុមទី ១ : ចំណាយពិត (ប្រភេទទី១ + ប្រភេទទី២)** |
| | | | **ប្រភេទទី ១ : អចលកម្ម** |
| 20 | | | **អចលកម្មអរូបី** |
| | 203 | | សោហ៊ុយសិក្សា ស្រាវជ្រាវ និង អភិវឌ្ឍន៍ |
| | 205 | | ប្រកាសនីយបត្រ.អាជ្ញាប័ណ្ណនិងសិទ្ធិប្រហាក់ប្រហែល |
| 21 | | | **អចលកម្មរូបី** |
| | 211 | | ដីធ្លី និងធនធានធម្មជាតិ |
| | 212 | | ការរៀបចំកែលំអរដីធ្លី |
| | 213 | | សំណង់ |
| | | 2131 | អាគារ |
| | | 2132 | ការរៀបចំកែលំអរអាគារ |
| | | 2138 | សំណង់ផ្សេងៗទៀត |
| | 214 | | ហេដ្ឋារចនាសម្ព័ន្ធ |
| | | 2141 | បណ្តាញបង្ហូរទឹក និងអនាម័យ |
| | | 2142 | បណ្តាញអគ្គិសនី |
| | | 2143 | បណ្តាញធារាសាស្ត្រ |
| | | 2144 | បណ្តាញផ្លូវថ្នល់ |
| | 215 | | បំបនកម្មបច្ចេកទេស សំភារៈ និងហត្ថូបករណ៍ |
| | | 2151 | បំបនកម្មបច្ចេកទេស |
| | | 2152 | សំភារៈ |
| | | 2153 | គ្រឿងឧបករណ៍ (ហត្ថូបករណ៍) |
| | 218 | | អចលកម្មរូបីយ៍ផ្សេងទៀត |
| | | 2181 | សំភារៈឧបករណ៍ដឹកជញ្ជូន |
| | | 2182 | សំភារៈឧបករណ៍ការិយាល័យ |
| | | 2183 | សំភារៈពត៌មានវិទ្យា និងទូរគមនាគមន៍ |
| | | 2184 | សង្ហារឹម |
| | | 2188 | ផ្សេងៗ |
| | | | **ខ_ក្រុមទី ២ : ចំណាយតាមដីកា** |
| | | | **ប្រភេទទី ២ : ចំណាយតាមដីកា** |

ឧបសម្ព័ន្ធ១

# មាតិកាចំណូលថវិកាស្រុក_ខណ្ឌ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល |
|---|---|---|---|
| | | | **សរុបរួមចំណូលថវិកាស្រុក_ខណ្ឌ** |
| | | | **I - សរុបចំណូលចរន្ត** |
| | | | **ក. ក្រុមទី១ : ចំណូលពិត ( ប្រភេទទី១ + ប្រភេទទី២ )** |
| | | | **ប្រភេទទី ១: ចំណូលសារពើពន្ធ** |
| 70 | | | ចំណូលសារពើពន្ធ |
| | | | **ប្រភេទទី ២: ចំណូលមិនមែនសារពើពន្ធ** |
| 72 | | | **ផលខុនទៃទ្រព្យសម្បត្តិរដ្ឋ** |
| 73 | | | **ផលខុនលើការលក់-ជួលទ្រព្យសម្បត្តិនិងសេវា** |
| | 732 | | ផលពីការគ្រប់គ្រងរដ្ឋបាល |
| | | 7321 | សេវាសុរិយោដី |
| | | 7322 | សេវាសំណង់ |
| | | 7323 | ចំណូលសំរាប់ទំរង់ការរដ្ឋបាល |
| | | 7324 | ចំណូលពីការអនុញ្ញាតរដ្ឋបាល |
| | | 7328 | ចំណូលរដ្ឋបាលផ្សេងៗទៀត |
| | 733 | | ការជួលទ្រព្យសម្បត្តិអចល័ត |
| 74 | | | **ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម** |
| | 741 | | ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម |
| 75 | | | **ការឧបត្ថម្ភកធន** |
| | 751 | | ទាយជ្ជទានសំរាប់ដំណើរការដែលឧបត្ថម្ភដោយថវិការខេត្ត ក្រុង |
| | 752 | | ទាយជ្ជទានសំរាប់ដំណើរការដែលឧបត្ថម្ភដោយថវិការដ្ឋ |
| | 758 | | ចំណូលឧបត្ថម្ភថវិកាពីប្រភពផ្សេងៗ |
| 77 | | | **ផលផ្សេងៗនិងផលពិសេស** |
| | 775 | | ផលពីការលក់អចលកម្ម |
| | | | **ខ_ក្រុមទី ២ : ចំណូលតាមជីកា ( ប្រភេទទី៣ )** |
| | | | **ប្រភេទទី ៣ : ចំណូលតាមជីកា ( មិនឆ្លងកាត់សាច់ប្រាក់ )** |
| 77 | | | **ផលផ្សេងៗនិងផលពិសេស** |
| 78 | | | **ការងារនៃរដ្ឋទេយ្យ** |
| | | | **II - សរុបចំណូលជាមូលធន** |
| | | | **ក_ក្រុមទី ១: ចំណូលពិត ( ប្រភេទទី១ + ប្រភេទទី២ )** |
| | | | **ប្រភេទទី ១: ឧបត្ថម្ភកធន** |
| 13 | | | **ឧបត្ថម្ភកធនវិនិយោគ** |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល |
|---|---|---|---|
| | 131 | | ឧបត្ថម្ភកធនទទួលសំភារៈបរិក្ខាទេរភាគី |
| ប្រភេទទី ២: ចំណូលតាមដីកា ( មិនឆ្លងកាត់សាច់ប្រាក់) | | | |
| | | | .............. |
| | | | ............... |
| ខ-ក្រុមទី ២: ចំណូលតាមដីកា | | | |
| ប្រភេទទី ៣: ចំណូលតាមដីកា ( មិនឆ្លងកាត់សាច់ប្រាក់) | | | |

# ឧបសម្ព័ន្ធ២

# មាតិកាចំណាយថវិកាស្រុក-ខណ្ឌ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | | **សរុបរួមចំណាយថវិកាស្រុក-ខណ្ឌ** |
| | | | **I - សរុបចំណាយចរន្ត** |
| | | | **ក.ក្រុមទី ១ : ចំណាយពិត (ប្រភេទទី១ + ប្រភេទទី២ + ប្រភេទទី៣ + ប្រភេទទី៤)** |
| | | | **ប្រភេទទី ១ : ទស្សោធយសេវា** |
| 60 | | | ការទិញ |
| | 601 | | សំភារៈផ្គត់ផ្គង់ថែទាំ |
| | | 6011 | សំភារៈផ្គត់ផ្គង់សំអាតនិងអនាម័យ |
| | | 6012 | សំភារៈផ្គត់ផ្គង់សំរាប់ថែទាំអាគារ |
| | | 6013 | សំភារៈផ្គត់ផ្គង់សំរាប់ថែទាំ ផ្លូវថ្នល់ ផ្លូវលំ ស្ពាន និងលូ |
| | | 6014 | សំភារៈផ្គត់ផ្គង់សំរាប់ថែទាំសំភារៈឧបករណ៍ |
| | | 6015 | ប្រេងឥន្ធនៈនិងប្រេងរំអិល |
| | 602 | | សំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល |
| | | 6021 | សំភារៈការិយាល័យនិងការបោះពុម្ព |
| | | 6022 | សៀវភៅមើល និង ឯកសារ |
| | | 6028 | ផ្សេងៗ |
| | 603 | | ស្បៀងអាហារ |
| | | 6031 | ស្បៀង |
| | 604 | | សំលៀកបំពាក់និងការតុបតែង |
| | | 6041 | ឯកសណ្ឋាន |
| | | 6042 | សំលៀកបំពាក់ការពារសុវត្ថិភាព |
| | | 6043 | មេដាយ( គ្រឿងឥស្សរិយយស ) |
| | | 6048 | ផ្សេងៗ |
| | 605 | | សំភារៈតូចតាច សង្ហារឹម និងសំភារៈបរិក្ខារ |
| | | 6051 | សំភារៈនិង បរិក្ខារ |
| | | 6052 | សង្ហារឹម |
| | | 6053 | សំភារៈប្រើប្រាស់ |
| | | 6058 | ផ្សេងៗ |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | 606 | | ថាមពល និង ទឹក |
| | | 6061 | អគ្គិសនី |
| | | 6062 | ទឹក |
| | | 6068 | ផ្សេងៗ |
| | 608 | | សំភារៈផ្គត់ផ្គង់ផ្សេងៗ |
| 61 | | | **សេវាខាងក្រៅ** |
| | 611 | | កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស |
| | 612 | | ការជួលមធ្យោបាយដឹកជញ្ជូន |
| | 613 | | ថ្លៃឈ្នួល និងបន្ទុក ( អសង្ហារឹម ) |
| | 614 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក |
| | 615 | | ការថែទាំ និងជួសជុល |
| | | 6151 | ការថែទាំដីធ្លី សួនច្បារ,រៀបជាដូរ |
| | | 6152 | ការថែទាំ ទីផ្សារ សត្តឃាតដ្ឋាន និងអាគារសាធារណៈ |
| | | 6153 | ការថែទាំជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងប្រពន្ធ័លូ |
| | | 6154 | ការថែទាំបណ្តាញផ្សេងៗ |
| | | 6155 | ការថែទាំ និងជួសជុលឧបករណ៍ សំភារៈការិយាល័យ សំភារៈពត៌មានវិទ្យា និងទូរគមនាគមន៍ |
| | | 6156 | ការថែទាំ និងជួសជុលមធ្យោយដឹកជញ្ជូន |
| | | 6157 | ការថែទាំ និងជួសជុលសំភារៈឧបករណ៍បច្ចេកទេស |
| | 616 | | សោហ៊ុយធានារ៉ាប់រង |
| | 617 | | សោហ៊ុយសិក្សាពិសោធ៍ សោហ៊ុយនៃការប្រើប្រាស់សេវានិង សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ |
| | | 6171 | សោហ៊ុយសិក្សាពិសោធន៍ |
| | | 6172 | សោហ៊ុយនៃការប្រើប្រាស់សេវា |
| | | 6173 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ |
| | 618 | | សោហ៊ុយដឹកជញ្ជូន |
| | | 6181 | សំភារៈ និងទំនិញ |
| 62 | | | **សេវាខាងក្រៅផ្សេងៗ** |
| | 621 | | បុគ្គលិកខាងក្រៅ |
| | | 6211 | ភ្នាក់ងារជាតិជាប់កិច្ចសន្យា |
| | | 6212 | ភ្នាក់ងារបរទេសជាប់កិច្ចសន្យា |
| | | 6213 | បុគ្គលិកសមូហភាពសាធារណៈផ្សេងៗ |
| | 622 | | ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ |
| | | 6221 | សោហ៊ុយទទួលភ្ញៀវជាតិ |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | 6222 | សោហ៊ុយទទួលភ្ញៀវបរទេស |
| | | 6223 | ប្រជុំ -សិក្ខាសាលា និងសន្និសីទ |
| | | 6224 | សោហ៊ុយពិធីបុណ្យ |
| | | | . បុណ្យជាតិ និងបុណ្យប្រពៃណីយ៍ |
| | | | . បុណ្យចំរើនព្រះជន្មាយុព្រះមហាក្សត្រ |
| | | | . បុណ្យរុក្ខទិវា |
| | | | . បុណ្យផ្សេងៗទៀត |
| | | 6225 | ចំណាយសំរាប់វត្ថុអនុស្សាវរីយ៍ក្នុង និងក្រៅប្រទេស |
| | | 6226 | សោហ៊ុយសំរាប់ការតាំងពិពណ៌នៅក្នុងនិងក្រៅប្រទេស |
| | | 6227 | ការឃោសនានិងផ្សព្វផ្សាយពត៌មានសាធារណៈ |
| | 623 | | សោហ៊ុយជាវសារពត៌មាន និងឯកសារ |
| | 624 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស |
| | | 6241 | សោហ៊ុយដឹកជញ្ជូន |
| | | 6242 | សោហ៊ុយបេសកកម្ម |
| | | 6243 | សោហ៊ុយស្នាក់នៅ |
| | 625 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស |
| | | 6251 | សោហ៊ុយដឹកជញ្ជូន |
| | | 6252 | សោហ៊ុយបេសកកម្ម |
| | | 6253 | សោហ៊ុយស្នាក់នៅ |
| | 626 | | សោហ៊ុយទូរគមនាគមន៍ ទូរស័ព្ទតេឡិច និងទូរសារប្រៃសណីយ៍ |
| | | 6261 | សោហ៊ុយប្រៃសណីយ៍ |
| | | 6262 | សោហ៊ុយទូរគមនាគមន៍ |
| | 627 | | សោហ៊ុយធនាគារ |
| | 628 | | សោហ៊ុយផ្សេងៗ |
| 64 | | | **បន្ទុកបុគ្គលិក** |
| | 641 | | លាភការ និង ប្រាក់បំណាច់ នៃអំណាចសាធារណៈ |
| | | 6411 | ប្រាក់បំណាច់អភិបាលស្រុក-ខណ្ឌ |
| | | 6412 | ប្រាក់បំណាច់អភិបាលរងស្រុក-ខណ្ឌ |
| | | 6419 | ការសង និងការបង្វិលវិញ |
| | 642 | | លាភការនិងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ |
| | | 6421 | បៀវត្សមូលដ្ឋាន |
| | | | . ចំនួន |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | | . ប្រភេទ |
| | | | . ខុទ្ទកាល័យ |
| | | 6422 | ប្រាក់បំណាច់មុខងារ |
| | | 6423 | ប្រាក់បំណាច់ម៉ោងបន្ថែម |
| | | 6424 | ប្រាក់បំណាច់តំបន់ |
| | | 6425 | ប្រាក់បំណាច់ទទួលខុសត្រូវ |
| | | 6426 | ប្រាក់បំណាច់ការងារធ្ងន់ និងប៉ះពាល់សុខភាព |
| | | 6429 | ការសង និងការបង្វិលវិញ |
| | 643 | | រង្វាន់ និងប្រាក់បំណាច់ផ្សេងៗទៀត |
| | | 6431 | កន្សោមអទិភាព |
| | | 6432 | ប្រាក់បំណាច់សំរាប់ប្រឡង-ប្រឡងប្រជែង |
| | | 6433 | រង្វាន់ |
| | | 6434 | ប្រាក់បំណាច់បុគ្គលិកក្រសួងផ្សេងៗ |
| | | 6438 | ផ្សេងៗ |
| | | 6439 | ការសង និងការបង្វិលវិញ |
| | 644 | | លាភការ និងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ និងបុគ្គលិកអណ្តែត |
| | | 6441 | បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ |
| | | 6442 | លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខ័ណ្ឌ |
| | | 6443 | បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត |
| | | 6444 | លាភការផ្សេងៗទៀតបុគ្គលិកអណ្តែត |
| | | 6449 | ការសង និងការបង្វិលវិញ |
| | 645 | | ប្រាក់វិភាជន៍សង្គម |
| | | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ |
| | | | . កូនមានអាយុតិចជាង១៨ ឆ្នាំ |
| | | | . កូនរៀនវិទ្យាល័យ អនុវិទ្យាល័យ |
| | | | . ប្រាក់បំណាច់អ្នកក្នុងបន្ទុក |
| | | 6452 | មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសំរាលកូន |
| | | 6453 | មរណៈភាព |
| | | 6454 | ឧបត្ថម្ភនិវត្តជន |
| | | 6455 | ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ |
| | | 6456 | គ្រោះថ្នាក់ការងារ និងទពលភាព |
| | | 6457 | ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | 6458 | ផ្សេងៗ |
| | | 6459 | ការសង និងការបង្វិលវិញ |
| | | | **ប្រភេទទី ២ : បន្ទុកហិរញ្ញវត្ថុ** |
| 66 | | | **បន្ទុកហិរញ្ញវត្ថុ** |
| | | | **ប្រភេទទី ៣ : អន្តរាគមន៍សាធារណៈ** |
| 65 | | | **ឧបត្ថម្ភកធន និងជំនួយសង្គម** |
| | 651 | | ឧបត្ថម្ភកធនដល់រដ្ឋបាលដែនដី |
| | | 6511 | ឧបត្ថម្ភកធនដល់ឃុំ សង្កាត់ |
| | | 6512 | ឧបត្ថម្ភគ្រឹះស្ថានសាធារណៈរដ្ឋបាល |
| | 652 | | ជំនួយសង្គមនិងប្រាក់វិភាជន៍ |
| | | 6521 | ជំនួយដល់ប្រជាជនក្រីក្រសំរាកពេទ្យ |
| | | 6522 | ជួយជនរងគ្រោះដោយធម្មជាតិ |
| | | 6528 | ចំណាយសង្គមផ្សេងៗទៀត |
| | 653 | | ឧបត្ថម្ភកធនដល់អង្គភាពមានលក្ខណៈសង្គមនិងវប្បធម៌ |
| | | 6531 | ឧបត្ថម្ភមណ្ឌលកុមារកំព្រា |
| | | 6532 | ឧបត្ថម្ភសហគមន៍ កីឡា និងវប្បធម៌ |
| | | 6533 | ឧបត្ថមកាកបាទក្រហម |
| | | | **ប្រភេទទី ៤ : ចំណាយអន្សេងៗ** |
| 63 | | | **ពន្ធ និង អាករ** |
| | 631 | | លតាប័ត្រ |
| | | | **ខ.ក្រុមទី ២ : ចំណាយតាមដីកា និងចំណាយមិនបានគ្រោងទុក (ប្រភេទទី៥ + ប្រភេទទី៦)** |
| | | | **ប្រភេទទី ៥ : ចំណាយតាមដីកា ( មិនឆ្លងសាច់ប្រាក់ )** |
| 67 | | | **បន្ទុកពិសេស** |
| | 671 | | ឥណទេយ្យដែលទទួលស្គាល់តែទារមិនបាន |
| | 675 | | តំលៃគណនេយ្យនៃចំណែកសកម្មបានលក់ (តំលៃនៅសល់) |
| 68 | | | **ទាយជ្ជទានអោយដល់រំលស់អចលកម្ម** |
| | 681 | | ទាយជ្ជទានអោយដល់រំលស់អចលកម្មអរូបី |
| | 682 | | ទាយជ្ជទានអោយដល់រំលស់អចល់កម្មរូបី |
| | | | **ប្រភេទទី ៦ : ចំណាយមិនបានគ្រោងទុក** |
| 09 | | | **ចំណាយមិនបានគ្រោងទុក** |
| | | | **II - សរុបចំណាយជាមូលធន** |
| | | | **ក.ក្រុមទី ១ : ចំណាយពិត (ប្រភេទទី១ + ប្រភេទទី២)** |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ |
|---|---|---|---|
| | | | **ប្រភេទទី ១ : អចលកម្ម** |
| 20 | | | **អចលកម្មអរូបី** |
| | 203 | | សោហ៊ុយសិក្សា ស្រាវជ្រាវ និង អភិវឌ្ឍន៍ |
| | 205 | | ប្រកាសនីយប័ត្រ.អាជ្ញាប័ណ្ណនិងសិទ្ធិប្រហាក់ប្រហែល |
| 21 | | | **អចលកម្មរូបី** |
| | 211 | | ដីធ្លី និងធនធានធម្មជាតិ |
| | 212 | | ការរៀបចំកែលំអរដីធ្លី |
| | 213 | | សំណង់ |
| | | 2131 | អាគារ |
| | | 2132 | ការរៀបចំកែលំអរអាគារ |
| | | 2138 | សំណង់ផ្សេងៗទៀត |
| | 214 | | ហេដ្ឋារចនាសម្ព័ន្ធ |
| | | 2141 | បណ្តាញបង្ហូរទឹក និងអនាម័យ |
| | | 2142 | បណ្តាញអគ្គិសនី |
| | | 2143 | បណ្តាញធារាសាស្ត្រ |
| | | 2144 | បណ្តាញផ្លូវថ្នល់ |
| | 215 | | ឋបនកម្មបច្ចេកទេស សំភារៈ និងហត្ថូបករណ៍ |
| | | 2151 | ឋបនកម្មបច្ចេកទេស |
| | | 2152 | សំភារៈ |
| | | 2153 | គ្រឿងឧបករណ៍ ( ហត្ថូបករណ៍) |
| | 218 | | អចលកម្មរូបីយ៍ផ្សេងទៀត |
| | | 2181 | សំភារៈឧបកណ៍ដឹកជញ្ជូន |
| | | 2182 | សំភារៈឧបករណ៍ការិយាល័យ |
| | | 2183 | សំភារៈពត៌មានវិទ្យា និងទូរគមនាគមន៍ |
| | | 2184 | សង្ហារឹម |
| | | 2188 | ផ្សេងៗ |
| | | | **ខ-ក្រុមទី ២ : ចំណាយតាមដីកា** |
| | | | **ប្រភេទទី ២ : ចំណាយតាមដីកា** |